**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអភិវឌ្ឍន៍ជនបទ**

លេខ : ១៥៦/១៤ ក.អ.ជ.ប្រក

ថ្ងៃព្រហស្បតិ៍ ៨កើត ខែជេស្ឋ ឆ្នាំមមី ព.ស ២៥៥៨

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មិថុនា គ.ស ២០១៤

# ប្រកាស

## ស្តីពី

## ការបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញមូលដ្ឋានខេត្តកំពត

## រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/ ៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ១២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បកចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ២០០១ ស្តីពីការធ្វើវិសោធនកម្មលើ អនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងអភិវឌ្ឍន៍ជនបទ

## សម្រេច

**ប្រការ១.**_ បង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញមូលដ្ឋានខេត្តកំពត ចំណុះឲ្យមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពត ដឹកនាំដោយគណៈកម្មាធិការគ្រប់គ្រងដែលមានសមាសភាពដូចខាងក្រោម ÷

| | | |
|---|---|---|
| ១. លោក ហ៊ី ស្វិន | អនុប្រធានមន្ទីរ | ជានាយកមជ្ឈមណ្ឌល |
| ២. លោក ទូច សីហា | ប្រធានការិយាល័យ | ជានាយករងមជ្ឈមណ្ឌល |
| ៣. លោក ទេស ចន្ទប្រសិទ្ធ | មន្ត្រីរដ្ឋបាល | ជាប្រធានផ្នែករដ្ឋបាល |

៤. លោកស្រី ហ៊ុន សោភី ប្រធានការិយាល័យ ជាប្រធានផ្នែកហិរញ្ញវត្ថុ
៥. លោក សុខ សំបូរ អនុប្រធានការិយាល័យ ជាប្រធានផ្នែកបច្ចេកទេស

**ប្រការ២._** មជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញមូលដ្ឋានខេត្តកំពត មានទីតាំងនៅក្នុងបរិវេណមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត ។

**ប្រការ៣._** មជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញមូលដ្ឋានខេត្តកំពត មានភារកិច្ចដូចខាងក្រោម ÷

- ត្រូវអនុវត្តស្របតាមគោលនយោបាយរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ក្នុងការផ្តល់ចំណេះដឹង ជំនាញវិជ្ជាជីវៈជូនប្រជាពលរដ្ឋក្រីក្រ យុវជនអត់ការងារធ្វើ និងជនដែលងាយរងគ្រោះ ដើម្បីឲ្យពួកគេ មានលទ្ធភាពស្វែងរកការងារ ឬបង្កើតមុខរបរចិញ្ចឹមជីវិត
- សម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធ និងអង្គការនានា ដើម្បីឲ្យកិច្ចដំណើរការរបស់មជ្ឈមណ្ឌលប្រព្រឹត្តទៅបានល្អ និងមានប្រសិទ្ធភាព
- លើកផែនការសកម្មភាពការងារស្តីពីការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ រយៈពេលខ្លី មធ្យម និងវែង
- រៀបចំគម្រោងថវិកាសម្រាប់កិច្ចដំណើរការប្រចាំឆ្នាំ ជូនក្រសួងអភិវឌ្ឍន៍ជនបទ និងម្ចាស់ជំនួយពាក់ព័ន្ធ សម្រាប់កិច្ចដំណើរការរបស់មជ្ឈមណ្ឌល
- ជ្រើសរើសគ្រូជំនាញតាមមុខវិជ្ជាស្របតាមតម្រូវការរបស់មជ្ឈមណ្ឌល
- ផ្សព្វផ្សាយ និងជ្រើសរើសសិក្ខាកាមឲ្យចូលរៀនទៅតាមមុខវិជ្ជា ដែលបានកំណត់ក្នុងផែនការ
- គ្រប់គ្រង និងថែរក្សាទ្រព្យសម្បត្តិ សម្ភារៈ ឧបករណ៍របស់មជ្ឈមណ្ឌលឲ្យបានគង់វង្ស
- រៀបចំរបាយការណ៍ស្តីពីលទ្ធផលការងារ ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូនក្រសួងអភិវឌ្ឍន៍ជនបទ និងម្ចាស់ជំនួយដែលពាក់ព័ន្ធ ។

**ប្រការ៤ ._** រាល់សេចក្តីប្រកាសទាំងឡាយណាដែលផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៥ ._** នាយកខុទ្ទកាល័យ អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេស អគ្គាធិការ គ្រប់ប្រធាននាយកដ្ឋាន ប្រធានមន្ទីរអភិវឌ្ឍន៍ខេត្តកំពត និងសាមីខ្លួន ដែលមានឈ្មោះក្នុងប្រការ ១ មានភារកិច្ចអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

**ជា សុផារ៉ា**

<u>ចម្លងជូន</u>
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- សាលាខេត្តកំពត

*" ដើម្បីជូនជ្រាប "*

- ដូចប្រការ ៥

*"ដើម្បីអនុវត្ត "*

-ឯកសារ-កាលប្បវត្តិ